www.kidworship.kr

# ចំណងជើង៖ តង្វាយរបស់ស្ត្រីមេម៉ាយ



97Page

**Narration** ថ្ងៃមួយព្រះយេស៊ូហើយនិងពួកសិស្សរបស់ទ្រង់បានចូលទៅក្នុងព្រះវិហារ
ពេលនោះទ្រង់បានអង្គុយនៅខាងមុខហិបតង្វាយ។
ព្រះយេស៊ូទ្រង់ទតមើលពីរបៀបដែលបណ្តាជន យកប្រាក់មកដាក់នៅក្នុងហិបតង្វាយ។
បុរសអ្នកមានបានដាក់ប្រាក់ជាច្រើនទៅក្នុងហិបតង្វាយ។

**បុរសអ្នកមាន** អឺម..... ពិតជាធ្ងន់មែន..........!

**Narration** បុរសអ្នកមានបានបើកថង់ប្រាក់របស់គាត់
ហើយយកប្រាក់ចេញមកខាងក្រៅដើម្បីឲ្យមនុស្សគ្រប់គ្នាបានឃើញ
រួចយកចំណែកនៃប្រាក់របស់គាត់ដាក់ទៅក្នុងហិបដង្វាយ ។
មនុស្សគ្រប់គ្នាបាននិយាយខ្សឹបខ្សៀវគ្នា
នៅពេលដែលឃើញបុរសអ្នកមានបានដាក់ប្រាក់យ៉ាងច្រើនទៅក្នុងហិបដង្វាយ។

**មនុស្សទី១** ហេ! មើលណ៎! គាត់ពិតជាមានប្រាក់ច្រើនមែន...

**មនុស្សទី២** មើលទៅតង្វាយរបស់គាត់ទៅ គឺច្រើនណាស់ ! ជំនឿរបស់គាត់ប្រាកដជារឹងមាំហើយ។

**មនុស្សទី១** អ្នកនិយាយនេះត្រូវហើយ ព្រះប្រាកដជាប្រទានពរសំរាប់គាត់
ព្រោះគាត់បានថ្វាយតង្វាយច្រើនណាស់ទៅព្រះ។

.......................................................................................................



98Page

**Narration** បន្ទាប់ពីអ្នកមាននោះបានចេញទៅបាត់
មានស្ត្រីមេម៉ាយម្នាក់បានចូលមកដោយស្លៀកសំលៀកបំពាក់រយ៉េរយ៉ាក
ឈរនៅមុខហិបតង្វាយ។ ទោះបីនៅទីនោះមានមនុស្សច្រើនយ៉ាងណាក្តី
ក៏គ្មាននរណាម្នាក់បានយកចិត្តទុកដាក់នឹងនាងឡើយ។

**ស្ត្រីមេម៉ាយ** នេះជាប្រាក់ទាំងអស់ដែលខ្ញុំមាន។ ខ្ញុំពិតជាអស្ចារ្យណាស់ដែលខ្ញុំអាចមានប្រាក់ខ្លះ
ក្នុងការថ្វាយជាតង្វាយ ទៅព្រះជាម្ចាស់។

**Narration** ស្ត្រីមេម៉ាយក្រីក្រនាងបានយកប្រាក់ពីរសេន ជាចំនួនដ៏តិចតួចបំផុតដាក់ក្នុងហិបតង្វាយ។
តង្វាយរបស់នាងមានតម្លៃប្រហែលជា ២០០ ទៅ ៣០០ វ៉ុន( រូបិយប័ណ្ណកូរ៉េ) ប៉ុណ្ណោះ។

.......................................................................................................



99Page

ក្រឹង (សំឡេងកាក់ធ្លាក់)

**Narration** នៅពេលដែលមនុស្សម្នាបានឮសំឡេង កាក់ធ្លាក់ចូលក្នុងហិបតង្វាយ ពួកគេបានសើច
ស្ត្រីមេម៉ាយនោះ។

**មនុស្សទី១** ទូក.....ទូក....មិនដឹងថាថ្វាយទៅកាន់ព្រះជាម្ចាស់យ៉ាងម៉េចទេ បើតង្វាយតិចដូច្នេះនោះ?

**មនុស្សទី២** នាងប្រាកដជាមានជំនឿតិចតួចណាស់ហើយ!

**មនុស្សទី១** ខ្ញុំនឹងខិតខំរកលុយឲ្យបានច្រើន បន្ទាប់មកខ្ញុំនឹងថ្វាយទៅព្រះជាម្ចាស់
ដូចជាបុរសអ្នកមានម្នាក់នោះអម្បិញមិញអញ្ចឹង។



100Page

**Narration** មានអ្នកខ្លះបានមើលទៅព្រះយេស៊ូដោយភាពស្ងៀមស្ងាត់។
ពេលនោះព្រះយេស៊ូបានហៅពួកសិស្សរបស់ទ្រង់រួចមានព្រះបន្ទូលថា៖

**ព្រះយេស៊ូ** ខ្ញុំសូមប្រាប់អ្នករាល់គ្នាឲ្យដឹងច្បាស់ថា ស្ត្រីមេម៉ាយក្រីក្រម្នាក់នេះ
បានដាក់ប្រាក់តង្វាយទៅក្នុងហិបតង្វាយច្រើនជាងបុរសម្នាក់នោះទៅទៀត។

**ពួកសិស្ស** តើលោកគ្រូចង់មានន័យយ៉ាងដូចម្ដេច?
បុរសអ្នកមានបានថ្វាយតង្វាយទៅកាន់ព្រះជាម្ចាស់យ៉ាងច្រើន
ប៉ុន្តែស្ត្រីមេម៉ាយម្នាក់នេះវិញ នាងបានថ្វាយត្រឹមតែពីរសេនប៉ុណ្ណោះ។

**ព្រះយេស៊ូ** ដ្បិតពួកទាំងនោះ បានយកសំណល់ប្រាក់របស់ពួកគេមកថ្វាយប៉ុណ្ណោះ
រីឯស្ត្រីមេម៉ាយម្នាក់នេះវិញ ទោះបីនាងក្រីក្រយ៉ាងណាក៏ដោយ
ក៏នាងបានយកប្រាក់ដែលនាងត្រូវការជាចាំបាច់មកថ្វាយដែរ
គឺប្រាក់ទាំងប៉ុន្មានដែលនាងមានសំរាប់ចិញ្ចឹមជីវិត។



101Page

**Narration** ព្រះទ្រង់មិនមែនមើលផ្ដោតសំខាន់ទៅលើរូបរាងខាងក្រៅរបស់យើងឡើយ។
ហើយទ្រង់ក៏មិនដែលទតមើលពីតង្វាយដែលយើងថ្វាយទៅកាន់ទ្រង់នោះដែល
គឺទ្រង់ចង់ឲ្យយើងមាននូវសេចក្ដីស្រឡាញ់និងភាពស្មោះត្រង់ចំពោះទ្រង់តែប៉ុណ្ណោះ។